# សិលាចារឹករកឃើញថ្មីនៅទួលម្ទេស ខេត្តបាត់ដំបង

សិលាចារឹកនេះសព្វថ្ងៃរក្សាទុកនៅវត្តទួលពន្ធៃ ភូមិអូរស្រឡៅ ឃុំវត្តតាមឹម ស្រុកសង្កែ ខេត្តបាត់ដំបង។ យោងតាមសង្ឃដីការបស់ព្រះតម្លេងសង្ឃ ផុន សាវេត ព្រះគ្រូចៅអធិការវត្តទួលពន្ធៃ មានសង្ឃដីកាថា សិលាចារឹកនេះរកឃើញនៅទួលម្ទេស ភូមិទួលម្ទេស ឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដែលរកឃើញដោយលោក សុយ ប្រាក់ នៅរវាងឆ្នាំ២០១២ ក្នុងពេលភ្ជួរដីស្រែក្បែរបុរាណដ្ឋានទួលម្ទេស។ ក្រោយមក ព្រះគ្រូចៅអធិការវត្ត ក៏បានយកមករក្សាទុកនៅវត្តពន្ធៃរហូតមក។ តើសិលាចារឹកវត្តពន្ធៃ មានអត្ថន័យ និងខ្លឹមសារយ៉ាងណាខ្លះ?

ខ្ញុំបានទទួលព័ត៌មានសិលាចារឹកនេះពីព្រះតម្លេងសង្ឃ ឆាយ ទីន នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤។ សិលាចារឹកនេះ ចារឹកជាភាសាខ្មែរមានចារឹកអក្សរចំនួន ១៤ បន្ទាត់ ចារនៅលើបន្ទះថ្មភក់។ អក្សរចារឹកនេះ ជាប្រភេទអក្សរជ្រៀង ដោយនៅត្រង់ផ្នែកខាងឆ្វេងខាងលើ មានបែកបាក់ថ្មដែលធ្វើឱ្យបាត់កាលបរិច្ឆេទរបស់សិលាចារឹកនេះ។ សិលាចារឹកនេះ ចារឹកនៅសម័យអង្គរ នាពាក់កណ្ដាលស.វ.ទី១០ ដោយទំហំទទឹង ០,៣០ ម៉ែត្រ និងកម្ពស់ ០,៣២ ម៉ែត្រ។

អត្ថន័យជាទូទៅរបស់សិលាចារឹកនេះ គឺជាប្រភេទព្រះរាជសាសន៍ (សេចក្ដីណែនាំត្រាស់បង្គាប់) ឱ្យដល់រដ្ឋមន្ត្រីជាន់ខ្ពស់ម្នាក់ ដែលមានឋានន្តរនាមថា "ម្រតាញអញ"។ ត្រង់កន្លែងឈ្មោះរបស់ម្រតាញអញ គឺបានបាក់បែកថ្ម តែយើងអាចកាត់យល់បានថាជា"**ម្រតាញស្រីកវីន្ទ្រារិមថន**" ដែលជារដ្ឋមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកកិច្ចការខាងព្រះពុទ្ធសាសនា ក្នុងរជ្ជកាលព្រះបាទស្រីរាជេន្ទ្រវម៌្មទេវ។ រដ្ឋមន្ត្រីម្រតាញស្រីកវីន្ទ្រារិមថន បានពាំនាំពាក្យបន្ទូលរបស់ព្រះរាជាទៅដល់អ្នកជំនិតជាច្រើននាក់ ដែលសុទ្ធសឹងមានគោរម្យងារជា "វាប" ដើម្បីប្រើឱ្យទៅធ្វើតង្វាយមូលនិធិដល់ទេវស្ថាន។ តង្វាយជាដីស្រែ គឺមានបញ្ជាក់ដល់ព្រំគោលសីមាដីស្រែ និងតង្វាយផ្សេងៗទៀតដែលមិនបានបញ្ជាក់ច្បាស់ តែគេគិតខ្នាតជាស្លឹក ហើយសេចក្ដីណែនាំនោះធ្វើឡើងនៅក្នុងខែខ្នើត (កើត) ក្នុងខែពិសាខ។

### អត្ថបទពាក្យចារឹក

១. ..........................កេត វៃគាខ

២. [នុ មាន ព្រះ] គា[ស]ន ត ម្រតាញ

៣. [អញ ស្រីកវិន្ទ្រារិម]ថន ប្រេ ឱយ

៤. ............ប្រេ កន្ទារ សុរភិ ត ទគាវសិកិ

៥. [ម្រតាញ ស្រីកវិ]ន្ទ្រារិមថន បន្ទូល ព្រះ

អត្ថបទដោយ៖ កំ វណ្ណារ៉ា

៦.　.......ត វាប...វ្យាស ប្រត្យយ

៧.　.....ឱយ ប្រសាទ ស្រេ កន្វារ សុរភិ ត ទ

៨.　គាវសិក៑ តោយ៑ ប្វូ៌ វ្នុ កនីក ស្តុក សំន្តា

៩.　ប៑ សុវណ៌ាចាលិ ទក្សិន គ្នង ឧត្តរគ្នង ទៅ បត្ឆិ

១០.　ម ស្តុក ប្រាសុរភិ គិ ត រាប ភាគ តទិង

១១.　ថ្ងាយ ភាគ វាប វ្រៅ ស្លិក ៣ វាប អក ស្លិក៣

១២.　វាប៑ ននិ ស្លិក១ វាប៑ អ្យក៑ ស្លិក៑១ វាប៑ កប៑ ស្លិក៑១

១៣.　វាប៑ ធម៌្ម គត៣ វាប៑ ថ្ងៃ គត៣ វាប៑ ស្រី

១៤.　ស្លិក៑ ២ ទៅ បត្ឆិម ទគាវស ស្លិក៑ ៧

**បំណកប្រែ**

*(បន្ទាត់ទី១ ដល់ទី ៣) ...............កើត ខែពិសាខ ព្រះមហាក្សត្រទ្រង់មានព្រះរាជតម្រាស់ត្រាស់ដល់ព្រះតេជគុណម្រតាញស្រីកវិន្ទ្រារិមថន ត្រាស់បង្គាប់ប្រើ ដើម្បីប្រគល់ឱ្យ .....។*

*(បន្ទាត់ទី៤ ដល់ទី ១៤) ..........ប្រើកន្វារសុរភិ ដែលជាទសវសិព្រះតេជគុណម្រតាញអញស្រីកវិន្ទ្រារិមថន បាននាំបន្ទូលព្រះរាជបញ្ជា ....ត្រាស់ដល់វាប ..វ្យាស ជាប្រត្យយ (ស្មោះភក្តី) ...ឱ្យប្រទានស្រែកន្វារ សុរភិ ដែលជាទសវសិក (ដោយដីស្រែនោះកំណត់) ដោយពីខាងកើត ទួលកនីក ស្តុក សន្តាប សុវណ៌ាចាលិ ខាងត្បូង គ្នង ខាងជើង គ្នង ទៅខាងលិច ដល់ ស្តុកប្រាសុរភិ គឺរហូតដល់ភាគខាងទទឹងថ្ងៃ (មាន) វាបវ្រៅចំនួន ៣ ស្ទឹក, វាបអក ៣ ស្ទឹក, វាបនន ១ ស្ទឹក, វាបអ្យក ១ ស្ទឹក, វាបកប ១ ស្ទឹក, វាបធម៌្មចំនួន ៣០០, វាបថ្ងៃចំនួន ៣០០, វាបស្រី ២ ស្ទឹក រហូតទៅដល់ខាងបស្ចឹមទសាវសិចំនួន ៧ ស្ទឹក។*

*ជារួមមក សិលាចារឹករកឃើញថ្មីនៅទួលម្ទេស ខេត្តបាត់ដំបង បានផ្តល់ព័ត៌មានឱ្យយើងដឹងអំពីព្រឹត្តិការណ៍នយោបាយក្នុងរាជ្យព្រះបាទស្រីរាជេន្ទ្រវរ្ម័ន ដែលមានរដ្ឋមន្ត្រីជាន់ខ្ពស់ម្នាក់ឈ្មោះ "ម្រតាញស្រីកវីន្ទ្រារិមថន" ជាអ្នកទទួលបន្ទុកការងារព្រះពុទ្ធសាសនា។ រដ្ឋមន្ត្រីរូបនេះបាននាំព្រះរាជតម្រាស់របស់ព្រះរាជា ទៅផ្សព្វផ្សាយដល់មន្ត្រីថ្នាក់ក្រោមឱ្យអនុវត្តតាម។ ក្រៅពីនេះយើងបានដឹងរឿងរ៉ាវមួយចំនួន ពាក់ព័ន្ធរឿងការការពារដីធ្លីរបស់ទេវស្ថាន។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*



រូបលេខ១៖ ការចុះផ្ដិតសិលាចារឹកទួលម្ទេស នៅវត្តពន្លៃ ខេត្តបាត់ដំបង



រូបលេខ២៖ សិលាចារឹកទួលម្ទេស រក្សាទុកនៅវត្តពន្លៃ ខេត្តបាត់ដំបង

អត្ថបទដោយ៖ កំ វណ្ណាវ៉ា



រូបលេខ៣៖ ក្រដាសផ្តិតសិលាចារឹកទួលម្ទេស (ផ្តិតដោយ៖ កំ វណ្ណារ៉ា និង ធាយ ទីន)

អត្ថបទដោយ៖ កំ វណ្ណារ៉ា